# របាំត្បាល់ក្តឿង

របាំត្បាល់ក្តឿង ជាប្រភេទរបាំប្រពៃណីខ្មែរ ត្រូវបានលោកគ្រូ ប៉ុក សារ៉ាន់ បង្កើតឡើងនៅពេលដែលលោកគ្រូរស់នៅក្នុងខេត្តកំពង់ធំ ក្រោយពីពេលរំដោះពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ ក្រោយមកទៀតទើបរបាំនេះ ត្រូវបានលោកព្រឹទ្ធាចារ្យ ឆេង ផុន កែច្នៃលម្អបន្ថែមព្រមទាំងបានសម្តែងជារៀងរហូតមកដល់សព្វថ្ងៃនេះ។

របាំនេះបង្ហាញពីរបស់របរប្រើប្រាស់ជាតិពន្ធុវិទ្យា និងឆ្លុះបញ្ចាំងពីរបៀបរស់នៅរបស់ប្រជាកសិករខ្មែរ ជាពិសេសក្នុងការប្រើប្រាស់ត្បាល់ក្តឿងឬត្បាល់ជាន់ដើម្បីបុកស្រូវយកអង្ករក៏ដូចជាធ្វើម្សៅ។ នៅកម្ពុជាយើង មានត្បាល់ជាច្រើនប្រភេទ រួមមានត្បាល់បក់ ត្បាល់ជាន់ឬត្បាល់ក្តឿង ត្បាល់បុក ត្បាល់កាប់ និងត្បាល់កិន ដែលប្រជាកសិករខ្មែរប្រើប្រាស់នៅទូទាំងប្រទេស។ ត្បាល់ខ្លះ គឺគេត្រូវប្រើជាគូជាមួយនឹងអង្រែផង ដូចជាត្បាល់បុកនិងត្បាល់កាប់ ដែលគេចាត់ទុកថាត្បាល់គឺញី ឯអង្រែគឺឈ្មោល។

នាបច្ចុប្បន្នកាល កសិករខ្មែរប្រើបច្ចេកវិទ្យានិងម៉ាស៊ីន រួមទាំងរបៀបនិងប្រព័ន្ធថ្មីដើម្បីកិនស្រូវយកអង្ករនិងធ្វើម្សៅ។ យ៉ាងណាមិញ នៅតាមទីជនបទដាច់ស្រយាលដែលបច្ចេកវិទ្យានិងម៉ាស៊ីននៅមិនទាន់ចូលទៅដល់ គេក៏នៅប្រើប្រាស់ត្បាល់បុរាណដែលបានរៀបរាប់ខាងលើនៅឡើយ។ នៅក្នុងរបាំត្បាល់ក្តឿង គ្រូបង្កើតរបាំ សិល្បករ និងសិល្បការិនីយើង មានទេពកោសល្យច្នៃប្រឌិតរបាំនេះ ដោយបញ្ចូលរួមគ្នានូវឧបករណ៍របាំមានត្បាល់ក្តឿងជាមួយនឹងអង្រែកាប់។

## ឯកសារពិគ្រោះ

Sam, Chan Moly, Nguon, Sam Ath, and Sam, Sam-Ang

អត្ថបទដោយ៖

អត្ថបទ៖

អត្ថបទដោយ៖

អត្ថបទ៖





អត្ថបទដោយ៖





ប្រភពរូបភាពខាងលើក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

អត្ថបទដោយ៖

អត្ថបទ៖

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖